**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

មហាអយ្យការសាលាឧទ្ធរណ៍
លេខ ៤២៣/០៣

# អគ្គព្រះរាជអាជ្ញាមហាអយ្យការសាលាឧទ្ធរណ៍ភ្នំពេញ

**សូមជម្រាបមក**

## លោកព្រះរាជអាជ្ញាតុលាការខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។

**កម្មវត្ថុ:** អំពីភារៈកិច្ចអនុវត្តបញ្ញត្តិច្បាប់វិសោធនកម្មមាត្រា៣៦ ថ្មី ៣៨ ថ្មី និងអនុវត្តបញ្ញត្តិផ្សេងទៀត នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

តាមការត្រួតពិនិត្យផ្សេងៗ ខ្ញុំបានសង្កេតឃើញថា លោកព្រះរាជអាជ្ញាមិនខាន់បានអនុវត្តភារៈកិច្ចរបស់ខ្លួនបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដែលចែងអំពីតួនាទី និងភារៈកិច្ចរបស់ព្រះរាជអាជ្ញា ពិសេសកថាខ័ណ្ឌទី២ មាត្រា៣៦ថ្មី នៃច្បាប់នីតិវិធីព្រហ្មទណ្ឌដែលចែងយ៉ាងដូច្នេះ៖

-ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានការដឹកនាំ និងសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធី និងវិធានស៊ើបអង្កេត ដើម្បីធានាការចោទប្រកាន់អោយមានប្រសិទ្ធិភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍។

តាមបញ្ញត្តិខាងលើ ភារៈកិច្ចធំចម្បងដែលលោកព្រះរាជអាជ្ញាត្រូវបំពេញអាចមានបី(៣)

I-**ដឹកនាំ និងសម្របសម្រួលលើនីតិវិធី**

នីតិវិធី សំដៅយកបញ្ញត្តិច្បាប់ទាំងឡាយដែលចែងពីរបៀបរបបអោយអនុវត្ត ដូចជានីតិវិធីអនុវត្តក្នុងបទល្មើសជាក់ស្តែង អនុវត្តក្នុងបទល្មើសមិនជាក់ស្តែងវិធីទាក់ទងនិងពេលវេលាឆែកឆេរ បែបបទចំពោះមុខជនល្មើស ម្ចាស់ផ្ទះ សាក្សី ឬមជារី នីតិវិធីទាក់ទង និងកំណត់ពេលឃាត់ខ្លួនជនសង្ស័យ លក្ខខ័ណ្ឌទាក់ទងនិងការពន្យាពេលឃាត់ខ្លួន នីតិវិធីត្រូវបញ្ជូនសំណុំរឿងព្រហ្មទណ្ឌ នីតិវិធីត្រូវគោរពសម្រាប់កំណត់ហេតុមានតម្លៃគតិយុត្តិចែងក្នុងបញ្ញត្តិមាត្រា ៤២ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌជាដើម ។

នីតិវិធីទាំងអស់នេះ អាចផ្តល់តម្លៃភស្តុតាងប្រឆាំង និងជនត្រូវចោទ ។ ប៉ុន្តែផ្ទុយទៅវិញបើការអនុវត្តមានការខ្វះចន្លោះខុសឆ្គង ឬមានការរំលោភវិញនោះកំណត់ហេតុលែងមានតម្លៃដែលជាមូលហេតុនាំអោយជនល្មើសបានរួចខ្លួន ។ ដូច្នេះដើម្បីជាផលប្រយោជន៍ក្នុងការអនុវត្តច្បាប់អោយមានប្រសិទ្ធិភាព ត្រូវបំពេញបែបបទឡើងវិញដោយត្រូវស្វែងរកភស្តុតាងសាជាថ្មី ឬ ភស្តុតាងថ្មីបន្ថែមដែលជាកិច្ចការពិបាកខាតពេលវេលាប្រាក់កាស ឬត្រូវប្រើបច្ចេកទេសផ្សេង និងត្រូវប្រើធនធានមនុស្សថ្មីបន្ថែមទៀត ។

II-**ដឹកនាំ និងសម្របសម្រួលលើវិធានស៊ើបអង្កេត**

នីតិវិធីដែលអធិប្បាយខាងលើទាក់ទងនិងបញ្ញត្តិច្បាប់ ដែលចែងរៀបរាប់តម្រូវអោយគោរពតាម ឬហាមឃាត់មិនអោយបំពាន ។

ចំណែកឯវិធានស៊ើបអង្កេតវិញ របៀបរបបស៊ើបអង្កេតជាទម្លាប់ ប៉ុន្តែពិសេសគឺបច្ចេកទេសស៊ើបអង្កេតទាក់ទងនិងប្រភេទបទល្មើសនីមួយៗ គឺជាការងារអនុវត្តជាក់ស្តែងនៅទីកន្លែង ឬនៅលើអ្វីជាវត្ថុរូបីយ ឬអរូបីយដែលត្រូវបំពេញដែលប្រភេទការងារនេះទាក់ទងទាំងស្រុងទៅនិងប្រភេទនៃបទល្មើសផង ទៅនិងវិធីនៃអំពើដែលជនល្មើសបានជ្រើសរើសដើម្បីប្រព្រឹត្តបទល្មើសនោះផង ។

ដូច្នេះ បច្ចេកទេសស៊ើបអង្កេតនេះត្រូវតែចាត់ការ កាលណាបានពិនិត្យឬសង្កេតឃើញ នៅទីកន្លែងកើតហេតុជាក់ស្តែង ។

## III-ធានាការចោទប្រកាន់អោយមានប្រសិទ្ធិភាព

ខ្ញុំសូមរំលឹកថា បញ្ញត្តិមាត្រា១៣១ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងអំពីការប្តឹងទៅតុលាការ ក្នុងរឿងព្រហ្មទណ្ឌដែលមានសេចក្តី ៖

-មានតែអង្គអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។

ភ្ជាប់ជាមួយគោលការណ៍នេះ គប្បីពិចារណាលើគោលការណ៍ទាក់ទង និងចៅក្រម ដែលត្រូវតែអព្យាក្រិត្យមិនលំអៀង និងគោលការណ៍មិនផ្តេកផ្តួលជំនឿលើការដឹងឮផ្ទាល់ខ្លួន ដែលខ្លួនបានទទួលក្រៅពីសវនាការបញ្ញត្តិមាត្រា១២៥ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ក្នុងការកាត់ក្តី ឬ សម្រេចសេចក្តីលើបណ្តឹងអ្វីមួយ ។

ដូច្នេះ លោកព្រះរាជអាជ្ញា ដែលជាអ្នកធ្វើបណ្តឹងតាមបញ្ញត្តិមាត្រា២.៣.៤.៨ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌមានភារៈកិច្ចចង្អុលភស្តុតាង ដែលជាមូលដ្ឋាននាំអោយចៅក្រម ឬតុលាការ ជឿលើបណ្តឹង ហើយធ្វើការកាត់ទោសជនល្មើស ។ ជនល្មើសត្រូវបានតុលាការកាត់ទោស ត្រូវបាន អនុវត្តទោសក្នុងពន្ធនាគារ ត្រូវបានកែប្រែទៅជាប្រជាពលរដ្ឋល្អ ទើបអាចបញ្ជាក់ថា ការចោទប្រកាន់មានប្រសិទ្ធភាពទៅកើត ។

ដូច្នេះ ភារៈកិច្ចនេះធ្ងន់ធ្ងរមែនទែន ព្រមទាំងមានការទទួលខុសត្រូវក្នុងមុខនាទីនេះផង ដែលតម្រូវអោយលោកព្រះរាជអាជ្ញាយកចិត្តទុកដាក់អោយមែនទែន ។

ខ្ញុំសូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាថា នេះជាការបកស្រាយត្រួសៗចេញពីបញ្ញត្តិច្បាប់ ដែលលោកព្រះរាជអាជ្ញាសុទ្ធតែបានចេះដឹង ព្រមទាំងអនុវត្តជាហូរហែមកហើយ ការណ៍ដែលរាំងស្ទះឬឧបសគ្គនោះ គឺលោកព្រះរាជអាជ្ញាខ្វះធនធានមនុស្សជួយបំពេញភារៈកិច្ច ខ្វះថវិកាប៉ុណ្ណោះ ។ ប៉ុន្តែខ្ញុំសង្ឃឹមថាការងារបានដំណើរការល្អមិនអាចត្រូវតិទៀនបានឡើយ ។

ខ្ញុំសូមឆ្លៀតរំលឹកថា ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងធ្វើប្រកាសមួយណែនាំអំពីការអនុវត្តតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលគ្រប់មន្ត្រីនគរបាលយុត្តិធម៌ និងលោកព្រះរាជអាជ្ញា នឹងបានទទួលនៅពេលខាងមុខជាមិនខាន ។

ដូច្នេះ ដើម្បីអនុវត្តការងារទៅថ្ងៃមុខអោយមានប្រសិទ្ធិភាព ខ្ញុំសូមលោកព្រះរាជអាជ្ញារៀបចំការប្រជុំការងារជាមួយអស់លោកជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងខេត្ត-ក្រុងរបស់ខ្លួនអោយបានញឹកញាប់ ពិសេសខ្ញុំសូមអោយរៀបចំការប្រជុំ ដោយខ្ញុំនិងឯកឧត្តមអគ្គរងស្នងការនគរបាលជាតិ ឯកឧត្តម សូ ផន ឬ ឯកឧត្តម នេត សាវឿន និងចូលរួមដើម្បីជួយសម្រួល ប៉ុន្តែ អង្គប្រជុំស្ថិតនៅលើលោកព្រះរាជអាជ្ញាជាអ្នកដឹកនាំ ។ ដូច្នេះសូមលោកព្រះរាជអាជ្ញា ជួយផ្តល់នូវរបៀបវារៈដែលមានការកំណត់ពេលវេលាប្រជុំ និងប្រធានបទអោយខ្ញុំបានដឹង និងរៀបចំដើម្បីជៀសវាងការជាន់គ្នា ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣

**អគ្គព្រះរាជអាជ្ញា**

**ហង់រ៉ូ វ៉ាគេន**

<u>ចម្លងជូន</u>

-ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធតុលាការ
-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ឯកឧត្តម អគ្គស្នងការនគរបាលជាតិ
-ដើម្បីជ្រាបជាព័ត៌មាន ។
-ឯកឧត្តម សូ ផន និង នេត សាវឿន
-អគ្គរងស្នងការនគរបាលជាតិ
-ដើម្បីអញ្ជើញជួយសហការ
-អនុវត្តការងារឱ្យមានប្រសិទ្ធិភាព ។